-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ .-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន និងក្រុមហ៊ុន ដែលបានឧបត្ថម្ភថវិកា ក្នុងការជួយកសាងអគារសិក្សា នៅស្រុកបាកាន ខេត្តពោធិ៍សាត់ ដូចមានរាយនាមខាងក្រោម :-

១-ក្រុមហ៊ុន JAM SHIZUOKA បានផ្តល់ថវិកាចំនួន ៤៣.២១៩ ដុល្លារ តាមរយៈអង្គការ JHP ក្នុងការជួយកសាងអគារសិក្សា ចំនួន ០១ខ្នង មាន០៤បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារឹមគ្រប់គ្រាន់ និង បង្គន់អនាម័យ ០១ខ្នង មាន០៤បន្ទប់ ជូនដល់សាលាបឋមសិក្សាអន្លង់ក្រាយ ស្ថិតនៅភូមិអន្លង់ ក្រាយ ឃុំអូរតាប៉ោង ។

២-M.r INOUE AKIO បានផ្តល់ថវិកាចំនួន ៤២.០០០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ចំនួន ០១ខ្នង មាន០៣បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារឹមគ្រប់គ្រាន់ និង បង្គន់អនាម័យ ០១ខ្នង មាន០៤បន្ទប់ ជូនដល់សាលាបឋមសិក្សាប្រាសាទ ស្ថិតនៅភូមិប្រាសាទ ឃុំរលៀច ។

មាត្រា២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាល នៃគណៈអភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៧០ . អនក្រ . បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ .-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៣រូប ដែលបានឧបត្ថម្ភថវិកាសរុប ចំនួន ៤៣.២៣៧.៦៥ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សាថ្មី ចំនួន០១ខ្នង មាន០៥បន្ទប់ ជួសជុលអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ ជីកអណ្តូងទឹកស្អាត ០១ ព្រមទាំងទិញតុគ្រូ ១០ កៅអី១០ និងទិញតុសិស្ស ចំនួន១៣៥គ្រឿង ជូនដល់សាលាបឋមសិក្សាអង្គត្នោត ស្ថិតនៅក្នុងឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :-

១-Mr. TEP MOROKAD សប្បុរសជន

២-Mr. LECLAIR សប្បុរសជន

៣-Mr. TROUVE សប្បុរសជន

មាត្រា២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាល នៃគណៈអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៧៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ .-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូន Mr. WATANABE MIKI ប្រធានអង្គការ SCHOOL AID JAPAN ដែលបានឧបត្ថម្ភថវិកា ចំនួន ៥២.០០០ ដុល្លារអាមេរិក ក្នុងការជួយកសាង អគារសិក្សា ចំនួន០១ខ្នង មាន០៥បន្ទប់ ជូនដល់អនុវិទ្យាល័យអូរស្នូត ស្ថិតនៅឃុំអូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។

មាត្រា២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៧២ . អនក្រ . បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ខែក គឿន** សប្បុរសជន ដែលបានផ្តល់ថវិកាចំនួន ៣៦.១២០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៥បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់គ្រាន់ ជូនដល់វិទ្យាល័យអន្លង់វិល ស្ថិតនៅឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៧៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយថ្នាក់ស្ថាបនាជាតិ** ជូនលោកជំទាវ **យ៉ុ គិន** ភរិយាឯកឧត្តម **រុនផ្លាម កែសន** ដែលបានផ្តល់ថវិកាចំនួន ២៤.១៥៥.៨៨០ រៀល ក្នុងការជួយចេញថ្លៃសម្ភារៈជួសជុលអគារសិក្សា ទ្វារ-បង្អួច បន្ទប់ទឹក និងថ្លៃឈ្នួលជាង ជូនដល់សាលាបឋមសិក្សាទីរួមខេត្ត ស្ថិតនៅក្នុងខេត្តកោះកុង ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលនៃគណៈអភិបាលខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០១គ្រឿង ជូនអង្គការ **JESUIT SERVICE** ដែលបានផ្តល់ថវិកាសរុបចំនួន ៣៩.៨៨៦ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៥បន្ទប់ ធ្វើអំពីបេតុងប្រក់ក្បឿង ព្រមទាំងបំពាក់ តុ កៅអី សម្រាប់សិស្ស ចំនួន១២០ កំប្លេ តុ-កៅអីគ្រូ ចំនួន ០៥កំប្លេ និងក្តារខៀន ចំនួន ០៥ ជូនដល់សាលាបឋមសិក្សា តាំងគ្រួស ស្ថិតនៅឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ /

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧៥ . អនក្រ . បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០២រូប ដែលបានផ្តល់ថវិកាជួយសាងសង់អគារសិក្សា នៅខេត្តកំពង់ធំ ដូចមានរាយនាមខាងក្រោម :-

១-លោក **HONMA MASATO** ជនជាតិជប៉ុន បានផ្តល់ថវិកា ចំនួន ២០.៤៥៧,៧២ ដុល្លារ អាមេរិក ក្នុងការជួយកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៣បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារឹម គ្រប់បន្ទប់ បង្គន់អនាម័យ ០៤បន្ទប់ អណ្តូងទឹក ០១ និងដងទង់ជាតិ ០១ ជូនដល់សាលាបឋមសិក្សា ទួលធ្នង់ ស្ថិតនៅភូមិទួលធ្នង់ ឃុំគោល ស្រុកប្រាសាទសំបូរ ។

២-កញ្ញា **TALIA LEMAN** តំណាងអោយកុមារសកល ៧០រូប បានផ្តល់ថវិកា ចំនួនដូចខាងក្រោម ជួយដល់អនុវិទ្យាល័យកំពង់ក្របៅ ស្ថិតនៅភូមិស្វែងក្របី ឃុំកំពង់ក្របៅ ស្រុកស្ទឹងសែន :

- ថវិកា ចំនួន ៦២.៤៣៥,៧៦ ដុល្លារអាមេរិក ជួយកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៥បន្ទប់
- ថវិកា ចំនួន ៣.៨៤៥,១៤ ដុល្លារអាមេរិក ទិញគ្រឿងសង្ហារឹមបំពាក់គ្រប់បន្ទប់
- ថវិកា ចំនួន ១.២៥០ ដុល្លារអាមេរិក ជួយកសាងអណ្តូងទឹក ០១

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៧៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួនមួយគ្រឿង ជូន **Japan good price good house project** ដែលបានផ្តល់ថវិកាចំនួន ៤៩.៣៨៩ ដុល្លារអាមេរិក តាមរយៈអង្គការ JHP ក្នុងការជួយកសាងអគារសិក្សាចំនួន០១ខ្នង មាន០៤បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារឹមគ្រប់គ្រាន់ ជូនដល់សាលាបឋមសិក្សាស្វាយជ្រំ ស្ថិតនៅឃុំស្វាយជ្រំ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ៨ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៧៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួនមួយគ្រឿង ជូន **Satishome group** ដែលបានផ្តល់ថវិកាចំនួន ៥៥.៧៨៩ ដុល្លារអាមេរិក តាមរយៈអង្គការ JHP ក្នុងការជួយកសាងអគារសិក្សា ចំនួន ០១ខ្នង មាន០៤បន្ទប់ ព្រមទាំងបំពាក់បរិក្ខារគ្រប់គ្រាន់ និងបង្គន់អនាម័យ០១ខ្នង មាន០៤បន្ទប់ ជូនដល់ អនុវិទ្យាល័យរទាំង ស្ថិតនៅភូមិរទាំង ឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលនៃគណៈអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ HSR

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៧.សសរ

សេចក្តីសម្រេច

ស្តីពី

ការផ្ទេរក្របខ័ណ្ឌ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

ប្រការ១: ត្រូវបានផ្ទេរក្របខ័ណ្ឌ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូន វរសេនីយ៍ទោ **អ៊ុក គឹមសេង** អត្តលេខ ០១១៨៣៩ នាយរង ការិយាល័យហ្វឹកហ្វឺន កងពលតូចលេខ៧០ បច្ចុប្បន្នទៅ បំរើការងារក្នុងក្របខ័ណ្ឌ ក្រសួងព័ត៌មាន ។

ប្រការ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិងបណ្តាសមាសភាពដូចក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ៨/៣ ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ៩៤៧/៥៣១ ប្រក.កសក.សហវ

ប្រកាសរួម
ស្តីពី
តម្លៃទីផ្សារជាមូលដ្ឋាននៃផល អនុផលព្រៃឈើ ដើម្បីពិន័យអន្តរការណ៍

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
និង
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអនុក្រឹត្យទាំងឡាយដែលតម្លើង បំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអនុក្រឹត្យទាំងឡាយដែលតម្លើង បំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញការចាំបាច់

សម្រេច

ប្រការ ១ : ត្រូវបានកំណត់ឱ្យប្រើប្រាស់នូវតម្លៃទីផ្សារជាមូលដ្ឋាននៃឈើជ្រុង ឈើអារ តាមបណ្តារាជធានី ខេត្ត ដើម្បីពិន័យអន្តរការណ៍ នៅទូទាំងប្រទេសដូចក្នុងតារាងខាងក្រោម :

(គិតជារៀល/ម៣)

ល.រ	ខេត្ត	ឈើប្រណិត					ឈើ លេខ១	ឈើ លេខ២	ឈើលេខ៣ និង ក្រៅលំដាប់
		ក្រញូង	ក្រាក់ក្រញូង	បេង	នាងនួន	ធ្នង់			
១	សៀមរាប	៥ ៤៦០ ០០០	២ ១០០ ០០០	២ ៥២០ ០០០	២ ៥២០ ០០០	២ ១០០ ០០០	១ ១៧៦ ០០០	១ ០៥០ ០០០	៦៣០ ០០០
២	បន្ទាយមានជ័យ	៥ ៤៦០ ០០០	២ ១០០ ០០០	២ ៥២០ ០០០	២ ៥២០ ០០០	២ ១០០ ០០០	១ ២៦០ ០០០	១ ១៣៤ ០០០	៦៣០ ០០០
៣	ឧត្តរមានជ័យ	៥ ០៤០ ០០០	១ ៦៨០ ០០០	២ ១០០ ០០០	២ ១០០ ០០០	១ ៦៨០ ០០០	១ ០៥០ ០០០	៩២៤ ០០០	៦៣០ ០០០
៤	ព្រះវិហារ	៥ ០៤០ ០០០	១ ៦៨០ ០០០	២ ១០០ ០០០	២ ១០០ ០០០	១ ៦៨០ ០០០	១ ០៥០ ០០០	៩២៤ ០០០	៦៣០ ០០០
៥	កំពង់ធំ	៥ ៤៦០ ០០០	២ ១០០ ០០០	២ ៥២០ ០០០	២ ៥២០ ០០០	២ ១០០ ០០០	១ ១៧៦ ០០០	១ ០៥០ ០០០	៦៣០ ០០០
៦	ស្វាយរៀង	៦ ៣០០ ០០០	២ ៩៤០ ០០០	៣ ៣៦០ ០០០	៣ ៣៦០ ០០០	២ ៩៤០ ០០០	១ ៣០២ ០០០	១ ១៧៦ ០០០	៨៤០ ០០០
៧	ព្រៃវែង	៦ ៣០០ ០០០	២ ៩៤០ ០០០	៣ ៣៦០ ០០០	៣ ៣៦០ ០០០	២ ៩៤០ ០០០	១ ២១៨ ០០០	១ ១៧៦ ០០០	៨៤០ ០០០
៨	កំពង់ចាម	៦ ៣០០ ០០០	២ ៩៤០ ០០០	៣ ៧៨០ ០០០	៣ ៧៨០ ០០០	២ ៩៤០ ០០០	១ ១៣៤ ០០០	១ ០៥០ ០០០	៧១៤ ០០០
៩	ក្រចេះ	៦ ៣០០ ០០០	២ ៩៤០ ០០០	២ ៩៤០ ០០០	២ ៩៤០ ០០០	២ ១០០ ០០០	១ ០៥០ ០០០	៩២៤ ០០០	៦៣០ ០០០
១០	ស្ទឹងត្រែង	៥ ៤៦០ ០០០	២ ១០០ ០០០	២ ៥២០ ០០០	២ ៥២០ ០០០	១ ៦៨០ ០០០	១ ០៥០ ០០០	៩២៤ ០០០	៦៣០ ០០០
១១	រតនគិរី	៦ ៣០០ ០០០	២ ៩៤០ ០០០	២ ៥២០ ០០០	២ ៥២០ ០០០	២ ១០០ ០០០	១ ០៥០ ០០០	៩២៤ ០០០	៦៣០ ០០០
១២	មណ្ឌលគិរី	៥ ៨៨០ ០០០	២ ៥២០ ០០០	២ ១០០ ០០០	២ ១០០ ០០០	១ ៦៨០ ០០០	១ ០៥០ ០០០	៩២៤ ០០០	៦៣០ ០០០
១៣	កណ្តាល	៦ ៣០០ ០០០	២ ៩៤០ ០០០	៤ ២០០ ០០០	៤ ២០០ ០០០	៣ ៧៨០ ០០០	១ ៥១២ ០០០	១ ៣៨៦ ០០០	១ ០៥០ ០០០
១៤	ភ្នំពេញ	៦ ៣០០ ០០០	២ ៩៤០ ០០០	៤ ២០០ ០០០	៤ ២០០ ០០០	៣ ៧៨០ ០០០	១ ៥១២ ០០០	១ ៣៨៦ ០០០	១ ០៥០ ០០០
១៥	កំពង់ស្ពឺ	៥ ៤៦០ ០០០	២ ១០០ ០០០	២ ៩៤០ ០០០	២ ៩៤០ ០០០	២ ៥២០ ០០០	១ ១៧៦ ០០០	១ ០៥០ ០០០	៦៣០ ០០០
១៦	កំពង់ឆ្នាំង	៥ ៤៦០ ០០០	២ ១០០ ០០០	៣ ៣៦០ ០០០	៣ ៣៦០ ០០០	២ ៩៤០ ០០០	១ ២៦០ ០០០	១ ១៣៤ ០០០	៨៤០ ០០០
១៧	ពោធិសាត់	៥ ០៤០ ០០០	១ ៦៨០ ០០០	២ ៩៤០ ០០០	២ ៩៤០ ០០០	២ ៥២០ ០០០	១ ០៥០ ០០០	៩២៤ ០០០	៦៣០ ០០០
១៨	បាត់ដំបង	៥ ៤៦០ ០០០	២ ១០០ ០០០	៣ ៣៦០ ០០០	៣ ៣៦០ ០០០	២ ៩៤០ ០០០	១ ២៦០ ០០០	១ ១៧៦ ០០០	៨៤០ ០០០
១៩	ប៉ៃលិន	៥ ៤៦០ ០០០	២ ១០០ ០០០	២ ៥២០ ០០០	២ ៥២០ ០០០	២ ១០០ ០០០	១ ០៥០ ០០០	៩២៤ ០០០	៨៤០ ០០០
២០	កំពត	៦ ៣០០ ០០០	២ ៩៤០ ០០០	២ ៩៤០ ០០០	២ ៩៤០ ០០០	២ ៥២០ ០០០	១ ៤៧០ ០០០	១ ៣៨៤ ០០០	១ ០៥០ ០០០
២១	តាកែវ	៦ ៣០០ ០០០	២ ៩៤០ ០០០	៣ ៣៦០ ០០០	៣ ៣៦០ ០០០	២ ៩៤០ ០០០	១ ៥៩៦ ០០០	១ ៤៧០ ០០០	១ ០៥០ ០០០

២២	កែប	៦ ៣០០ ០០០	២ ៨៤០ ០០០	២ ៨៤០ ០០០	២ ៨៤០ ០០០	២ ៥២០ ០០០	១ ៥៨៦ ០០០	១ ៤៧០ ០០០	៨៦៦ ០០០
២៣	ព្រះសីហនុ	៦ ៣០០ ០០០	២ ៨៤០ ០០០	៣ ៣៦០ ០០០	៣ ៣៦០ ០០០	២ ៨៤០ ០០០	១ ៤៧០ ០០០	១ ៣៤៤ ០០០	៨៦៦ ០០០
២៤	កោះកុង	៥ ០៤០ ០០០	២ ៥២០ ០០០	២ ៨៤០ ០០០	២ ៨៤០ ០០០	២ ៥២០ ០០០	១ ០៥០ ០០០	៨២៤ ០០០	៦៣០ ០០០

ប្រការ ២ : រាល់តម្លៃទីផ្សារជាមូលដ្ឋាននៃផល អនុផលព្រៃឈើដទៃទៀត ដែលពុំមានចែងក្នុងប្រការ ១ ខាងលើ នឹងត្រូវកំណត់តម្លៃជាក្រោយ ។

ប្រការ ៣ : តម្លៃទីផ្សារជាមូលដ្ឋាននៃឈើជ្រុង ឈើអារ ដែលបានកំណត់ក្នុងប្រការ១ ខាងលើ នឹងធ្វើការពិនិត្យកែសម្រួលឡើងវិញជារៀងរាល់ឆ្នាំនៅខែឧសភា ហើយករណីចាំបាច់អាចត្រូវកំណត់ឡើងវិញ តាមតម្រូវការជាក់ស្តែង។

ប្រការ ៤ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ៥ : អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធានអង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១០

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ចាន់ សារុន

កន្លែងទទួល:

- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- ដូចប្រការ ៥
- គ្រប់សាលាខេត្ត-រាជធានី
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ [illegible] -ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ១១៥៨ /១០ គ.វ.ក ចុះថ្ងៃទី០៣.០៦.២០១០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ខ្វាន់ទុម អឺភែរឺល (ខេមបូឌា) លីមីធីត ចុះថ្ងៃទី២៥.០៥.២០១០

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន ខ្វាន់ទុម អឺភែរឺល (ខេមបូឌា) លីមីធីត តំណាងដោយ លោក MICHAEL DAVID SHOTTON សញ្ជាតិអង់គ្លេស អាយុ៥៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 099044435 ចុះថ្ងៃទី២៣.១១.២០០៧ មានអាសយដ្ឋានបច្ចុប្បន្ន៖ Bam Comer, Staircase Lane, Bramhope, Leeds LS16 8DB, England ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

-ឈ្មោះផលិតផល	លេខចុះបញ្ជីផលិតផល ISIC Code
សម្លៀកបំពាក់	៣២២០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥) -២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

-ផ្លាកឈ្មោះរោងចក្រ ៖" *ខ្វាន់ទុម អ៊ីភែរ៉ែល (ខេមបូឌា) លីមីធីត (QUANTUM APPAREL (CAMBODIA) LIMITED)*"

-ទីតាំងរោងចក្រ ៖" *ភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ*"

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាងគេ និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិរោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

ប្រការ១៥: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ សែម

ចម្លងជូន:
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ ១៣៧៩ ឧ.រ.ថ.ក.ចក.

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ ១៩១៥/១០ គ.វ.ក ចុះថ្ងៃទី០២.០៧.២០១០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន នីអាន់ យីដ (ខេមបូឌា) ចុះថ្ងៃទី០៥.០៧.២០១០

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន នីអាន់ យីដ (ខេមបូឌា) តំណាងដោយ លោក NYAN YEW LOONG សញ្ជាតិសឹង្ហបុរី អាយុ៣៧ឆ្នាំ កាន់លិខិតឆ្លងដែនលេខ E0491374B ចុះថ្ងៃទី០៤.១០.២០០៧ មានអាសយដ្ឋានបច្ចុប្បន្ន៖ 136B Hillwiew Avenue #07-03 S(669607) Singapore. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតសាខារោងចក្រ លើមុខសញ្ញាដូចខាងក្រោម ៖

-ឈ្មោះផលិតផល	លេខចុះបញ្ជីផលិតផល ISIC Code
ប៉ាក់ និងបោះពុម្ពសម្លៀកបំពាក់	៣២១២-៣៩២០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១. ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

-ផ្លាកឈ្មោះរោងចក្រ ៖ ***"នីអាន់ឃីដ (ខេមបូឌា) សាខាទី២ (NYAN KIDS (CAMBODIA) BRANCH N°2.)"***

-ទីតាំងរោងចក្រ ៖ ***"ភូមិឫស្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ"***

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មីនៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាម បទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

ប្រការ១១: លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោម តាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៥: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលារាជធានីភ្នំពេញ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

លេខៈ [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី០៣...ខែសីហា...ឆ្នាំ ២០១០

ប្រកាស

ស្តីពី

ក្រមសីលធម៌ វិជ្ជាជីវៈ សិល្បករ

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- បានឃើញ អនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- តាមការចាំបាច់របស់ក្រសួង

សម្រេច

ផ្នែកទី១

បទប្បញ្ញត្តិទូទៅ

ប្រការ ១.-

ប្រកាសនេះមានគោលដៅកំណត់អំពីក្រមសីលធម៌វិជ្ជាជីវៈសិល្បករ ក្នុងគោលបំណងលើកកម្ពស់អត្តចរិត សីលធម៌ សេចក្តីថ្លៃថ្នូរ គុណភាព និងច្នៃប្រឌិត ក្នុងការប្រកបមុខរបរវិជ្ជាជីវៈរបស់សិល្បករ ដើម្បីថែរក្សាការពារវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណីជាតិឱ្យបានគង់វង្ស ។.-

ប្រការ ២.-

ប្រកាសនេះមានវិសាលភាពគ្របដណ្តប់លើសិល្បករទូទៅ ដែលកំពុងប្រកបមុខរបរសិល្បៈគ្រប់មុខជំនាញទាំងអស់ ជាអ្នកបង្កើតស្នាដៃ អ្នកសម្តែង អ្នកបណ្តុះបណ្តាល និងអ្នកដឹកនាំគ្រប់គ្រងវិស័យសិល្បៈវប្បធម៌ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ផ្នែកទី២

គោលការណ៍គ្រឹះ

ប្រការ ៣.-

ក្រមសីលធម៌នេះកំណត់នូវគោលការណ៍គ្រឹះសំខាន់បីសម្រាប់សិល្បករទូទៅអនុវត្ត ÷

- សិល្បករ ត្រូវប្រកាន់ខ្ជាប់នូវវិន័យក្នុងការប្រកបមុខរបរវិជ្ជាជីវៈ
- សិល្បករ ត្រូវគោរពលក្ខខណ្ឌដែលកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិនានា ដើម្បីផលប្រយោជន៍សង្គមនិងរក្សាឱ្យបាននូវអត្តសញ្ញាណជាតិ
- សិល្បករ ត្រូវប្រកាន់ខ្ជាប់នូវឥស្សរភាពនៃវិជ្ជាជីវៈ ដែលមានជាអាទិ៍ : ឯករាជ្យភាព សន្តិភាព សេរីភាព និងឧត្តមភាព ក្នុងការបំពេញវិជ្ជាជីវៈរបស់ខ្លួន ដើម្បីរក្សាឱ្យបាននូវកិត្យានុភាពវប្បធម៌ជាតិ ។

ផ្នែកទី៣

ករណីយកិច្ចទូទៅរបស់សិល្បករ

ប្រការ ៤.-

សិល្បករ ត្រូវមានសមត្ថភាពជំនាញវិជ្ជាជីវៈណាមួយច្បាស់លាស់ ។

ប្រការ ៥.-

សិល្បករ ត្រូវមានស្មារតីសាមគ្គីភាព ស្នេហាជាតិ ស្នេហាវប្បធម៌ មានមនសិការក្នុងវិជ្ជាជីវៈជំនាញ ចូលរួមការងារសង្គម មិនប្រកាន់បក្សពួក គោរពតម្លៃអ្នកដទៃ បម្រើផលប្រយោជន៍រួមដើម្បីលើកតម្កើងសិល្បៈវប្បធម៌ជាតិ ។

ប្រការ ៦.-

សិល្បករ ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍សីលធម៌ ក្នុងសំណេរ កាយវិការ ពាក្យសំដី និងត្រូវរក្សាឱ្យបាននូវភាពថ្លៃថ្នូរដើម្បីលើកកម្ពស់សីលធម៌សង្គមនៅគ្រប់កាលៈទេសៈ ។

ប្រការ ៧.-

សិល្បករ ត្រូវស្វ័យសិក្សា និងស្រាវជ្រាវសម្រិតសម្រាំង បង្កើនចំណេះដឹងរបស់ខ្លួន និងចូលរួមក្នុងគ្រប់សកម្មភាពបណ្តុះបណ្តាលជាប្រចាំ ។

ប្រការ ៨.-

សិល្បករ ត្រូវតាំងចិត្តសម្រេចឱ្យបាន ការផ្ទេរចំណេះដឹង ការបណ្តុះបណ្តាលសិស្សសម្រាប់បន្តវេនជំនាញបច្ចេកទេសរបស់ខ្លួន ។

ប្រការ ៩.-

សិល្បករ ត្រូវស្រឡាញ់ការងារ ស្រឡាញ់ជំនាញ ត្រូវគោរពតម្លៃពិតខាងស្មារតី ខាងបច្ចេកទេស និងមិនត្រូវបន្ទាបបន្ថោកតម្លៃវិជ្ជាជីវៈសិល្បៈ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ។

ប្រការ ១០.-

សិល្បករ ត្រូវជៀសវាងពីអំពើទាំងឡាយណា ដែលធ្វើឱ្យអាប់ឱនដល់វិជ្ជាជីវៈសិល្បៈរបស់ខ្លួន ទោះស្ថិតនៅក្នុង ឬក្រៅក្របខណ្ឌវិជ្ជាជីវៈសិល្បៈក៏ដោយ ។

ប្រការ ១១.-

សិល្បករ ត្រូវជៀសវាងការបង្ករជម្លោះក្នុងក្រុមជាតិសាសន៍ តំបន់ សាសនា និងត្រូវជៀសវាងឱ្យបាននូវជំងឺបី គឺជំងឺជោរ ជំងឺប្រុសស្រី និងជំងឺលាភសក្ការៈ ។

ប្រការ ១២.-

សិល្បករ មិនត្រូវយកអំណាចក្នុងតួនាទីជាអាណាព្យាបាល ទៅបង្ខិតបង្ខំអ្នកក្រោមបង្គាប់ឱ្យប្រព្រឹត្តអំពើមិនគប្បីដែលនាំឱ្យប៉ះពាល់ដល់បទប្បញ្ញត្តិច្បាប់ ដល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់បុគ្គល និងសង្គមជាតិ ។

ប្រការ ១៣.-

សិល្បករ ត្រូវបានហាមឃាត់រាល់ការចូលរួម ការជួយដោយផ្ទាល់ ឬដោយប្រយោលដល់អ្នកដែលយកមុខរបរសិល្បៈទៅប្រព្រឹត្តអំពើខុសច្បាប់ណាមួយ ។

ផ្នែកទី៤
ករណីយកិច្ចរបស់អ្នកបង្កើតស្នាដៃ

ប្រការ ១៤.-

ការបង្កើតស្នាដៃត្រូវប្រមូលផ្តុំលើការអប់រំស្របតាមគោលនយោបាយវប្បធម៌របស់រដ្ឋនិងត្រូវរកឱ្យឃើញគោរពឱ្យបាននូវគោលការណ៍សច្ចធម៌ គុណធម៌ និងសោភ័ណភាពស្របតាមអត្តសញ្ញាណជាតិ ។

ប្រការ ១៥.-

រាល់ស្នាដៃដែលបានស្រាវជ្រាវរកឃើញ ត្រូវបញ្ជាក់ច្បាស់លាស់ពីប្រភព ទីកន្លែង ភូមិសាស្ត្រទឹកដី ប្រវត្តិរឿងរ៉ាវ សម័យកាល និងត្រូវជៀសវាងការយកឯកសារ ឬស្នាដៃអ្នកដទៃ មកធ្វើជារបស់ខ្លួន ។

ប្រការ ១៦.-

អ្នកបង្កើតស្នាដៃ មានករណីយកិច្ចគាំទ្រគ្រប់សកម្មភាពអប់រំ ផ្សព្វផ្សាយ រាល់កិច្ចការសង្គម និងត្រូវប្រកាន់ខ្ជាប់នូវមនសិការវិជ្ជាជីវៈរបស់ខ្លួន ។

ប្រការ ១៧.-

អ្នកបង្កើតស្នាដៃ ត្រូវតម្កល់ស្នាដៃរបស់ខ្លួនទុកជាកេរដំណែលសម្រាប់មនុស្សជំនាន់ក្រោយ ពិសេសឯកសារចងក្រងជាក្បួនតម្រា ដែលបានសិក្សាស្រាវជ្រាវរកឃើញ ។

ផ្នែកទី៥
ករណីយកិច្ចរបស់អ្នកសម្តែង

ប្រការ ១៨.-

អ្នកសម្តែង ត្រូវប្រកាន់ខ្ជាប់នូវមនសិការជំនាញ រក្សាឱ្យបាននូវភាពថ្លៃថ្នូរ ប្រកបដោយសីលធម៌ និងសុជីវធម៌ ទាំងកាយវិការ សម្លៀកបំពាក់ និងពាក្យសំដី ។

ប្រការ ១៩.-

អ្នកសម្តែង ត្រូវគោរពវិន័យឱ្យបានត្រឹមត្រូវ ទាំងក្នុងពេលហាត់សម មុនពេលសម្តែង ពេលកំពុងសម្តែង

និងក្រោយពេលសម្តែង ។

ប្រការ ២០.-

អ្នកសម្តែង ត្រូវព្យាយាមសិក្សារៀនសូត្រ ផ្លាស់ប្តូរបទពិសោធន៍ រវាងគ្នានិងគ្នា ដើម្បីបង្កើតសមត្ថភាព និងចំណេះដឹង ។

ប្រការ ២១.-

អ្នកសម្តែង មិនត្រូវយកអារម្មណ៍ពីខាងក្រៅទៅប្រើប្រាស់ក្នុងពេលសម្តែង ដែលនាំឱ្យប៉ះពាល់ ឬ ខូចខាតដល់គុណភាពសម្តែង ដល់កិត្តិយសសហការីរួមការងារជាមួយគ្នា និងត្រូវផ្ចង់អារម្មណ៍ដើម្បីលើកតម្លៃ ទាំងបច្ចេកទេស និងស្មារតីក្នុងការសម្តែង ។

ប្រការ ២២.-

អ្នកសម្តែង មិនត្រូវធ្វើឱ្យបាត់បង់មនសិការវិជ្ជាជីវៈជំនាញ ក្នុងការបំពេញកាតព្វកិច្ច និងករណីយកិច្ចរបស់ខ្លួនក្នុងការប្រកបវិជ្ជាជីវៈសិល្បៈក្រោមកិច្ចសន្យា ឬលក្ខខណ្ឌជាមួយស្ថាប័នសាធារណៈឬឯកជនណាមួយឡើយ។

ប្រការ ២៣.-

អ្នកសម្តែង មិនត្រូវយកភាពល្បីល្បាញរបស់ខ្លួន ទៅគាបសង្កត់ធ្វើឱ្យខូចប្រយោជន៍អ្នកដទៃ ទោះក្នុងរូបភាពណាក៏ដោយ ។

ផ្នែកទី៦
ករណីយកិច្ចរបស់អ្នកបណ្តុះបណ្តាល

ប្រការ ២៤.-

អ្នកបណ្តុះបណ្តាល ត្រូវយកអស់សមត្ថភាពដែលខ្លួនមានទាំងចំណេះដឹង និងបទពិសោធន៍បង្រៀនសិស្សដោយឥតលាក់លៀម នូវមុខវិជ្ជាឯកទេសដែលខ្លួនមាន ។ ៚

ប្រការ ២៥.-

អ្នកបណ្តុះបណ្តាល មានករណីយកិច្ចតែងការបង្រៀន និងកំណត់ការពន្យល់ ស្របតាមវិធីសាស្ត្របង្ហាត់បង្រៀន និងរៀន សំដៅធានាឱ្យបាននូវគុណភាព និងប្រសិទ្ធិភាពខ្ពស់ ។

ប្រការ ២៦.-

អ្នកបណ្តុះបណ្តាល ត្រូវមានករណីយកិច្ចជួយសិស្សដោយគ្មានការរើសអើង និងជួយបង្រៀនបន្ថែមដល់

សិស្សរៀនខ្សោយ និងត្រូវប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈ ដោយមិនត្រូវមើលរំលងទេពកោសល្យ ឧបនិស្ស័យ កាយសម្បទារបស់សិស្សក្នុងការបណ្តុះបណ្តាល ។

ប្រការ ២៧.-

អ្នកបណ្តុះបណ្តាល ត្រូវរក្សាទំនាក់ទំនងជាសហភាតរៈ សហការផ្លាស់ប្តូរបទពិសោធន៍ជាមួយសិល្បករដូចគ្នា ដើម្បីជាគំរូដល់សិស្ស និងរក្សានូវកិត្តិយសសេចក្តីថ្លៃថ្នូរ ។ក្នុងករណីមានទំនាស់ត្រូវចេះសម្រុះសម្រួលគ្នាក្នុងស្មារតីសាមគ្គីភាព ។

ប្រការ ២៨.-

រាល់ពេលបង្រៀន អ្នកបណ្តុះបណ្តាលត្រូវទុកដាក់ខ្លួនជាអាណាព្យាបាល និងជាគំរូល្អដល់សិស្សទូទៅដោយត្រូវស្លៀកពាក់ឱ្យបានសមរម្យ មានអាកប្បកិរិយាថ្លៃថ្នូរ ប្រើប្រាស់ពាក្យសំដីឱ្យមានសុជីវធម៌ និងត្រូវគោរពពេលម៉ោងបង្រៀន ។

ប្រការ ២៩.-

អ្នកបណ្តុះបណ្តាល មិនត្រូវផ្តល់ការសម្របសម្រួលគ្រប់បែបយ៉ាងដែលនាំឱ្យខ្លួនធ្វើខុសច្បាប់ និងបទបញ្ជាសិក្សាឡើយ ។

ជំពូកទី៧
ករណីយកិច្ចរបស់អ្នកគ្រប់គ្រង

ប្រការ ៣០.-

អ្នកគ្រប់គ្រង ត្រូវមានសមត្ថភាពគ្រប់គ្រាន់ មានបទពិសោធន៍ មានគំនិតផ្តួចផ្តើម មានចិត្តស្មោះត្រង់ មានយុត្តិធម៌ មានទំនាក់ទំនងល្អ និងឈ្លាសវៃក្នុងការដោះស្រាយបញ្ហាចំពោះមុខ ។

ប្រការ ៣១.-

អ្នកគ្រប់គ្រង ត្រូវធ្វើការផ្សព្វផ្សាយព័ត៌មានឱ្យបានគ្រប់គ្រាន់នូវរាល់វិធានច្បាប់ដែលទាក់ទងនឹងមុខវិជ្ជាជីវៈ។

ប្រការ ៣២.-

អ្នកគ្រប់គ្រង ត្រូវជួយយកចិត្តទុកដាក់ដល់សិល្បករក្នុងក្រុមឱ្យទទួលបានភាពយុត្តិធម៌ វិវត្តនីរីកចម្រើន និងមិនត្រូវដាក់សម្ពាធទាមទារផលប្រយោជន៍លើអ្នកក្រោមបង្គាប់ខ្លួនឡើយ ។

ប្រការ ៣៣.-

អ្នកគ្រប់គ្រង មិនត្រូវតម្កល់លាភសក្ការៈផលប្រយោជន៍ផ្ទាល់ខ្លួនជាធំ ទោះដោយផ្ទាល់ ឬដោយប្រយោល ដោយមើលរំលងទេពកោសល្យ ឧបនិស្ស័យ កាយសម្បទារបស់បុគ្គលក្នុងការជ្រើសរើសនោះឡើយ ។

ប្រការ ៣៤.-

អ្នកគ្រប់គ្រង មិនត្រូវដាក់ទណ្ឌកម្មខាងផ្លូវកាយ ឬផ្លូវចិត្តដល់អ្នកក្រោមឱវាទគ្រប់លំដាប់ថ្នាក់ ដោយខ្វះការពិចារណា ។ អ្នកគ្រប់គ្រង ត្រូវមានស្មារតីឈ្លាសវៃក្នុងការរិះគន់ស្ថាបនា និងការលើកទឹកចិត្ត ។

ប្រការ ៣៥.-

អ្នកគ្រប់គ្រង មិនត្រូវប្រព្រឹត្តសកម្មភាពខុសច្បាប់ដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់សិល្បករក្រោមឱវាទ ។

ផ្នែកទី៨

អវសានប្បញ្ញត្តិ

ប្រការ ៣៦.-

សិល្បករគ្រប់លំដាប់ថ្នាក់ ទាំងក្នុងអាជីពនិងមហាជនមានកាតព្វកិច្ចត្រូវគោរពតាមក្រមសីលធម៌វិជ្ជាជីវៈសិល្បករនេះ ។

ប្រការ ៣៧.-

នាយកខុទ្ទកាល័យ អធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ អគ្គនាយកបេតិកភណ្ឌ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ គ្រប់ប្រធានអង្គភាព នាយកដ្ឋានពាក់ព័ន្ធនិងប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហ៊ឹម ឆែម

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការ ៣៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៤៧៥០ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **រីថេល វីហ្សិន អេស៊ា**

RETAIL VISION ASIA Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ៦៣១៤/០៩E** ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩

មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **CHARLES BENCHETRIT** ប្រធានក្រុមប្រឹក្សាភិបាល

លោក **JACQUES BENCHETRIT** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ១០៨.000.000 រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ២០១ A&B (ជាន់ផ្ទាល់ដី ជាន់ទី១ ជាន់ទី២ ជាន់ទី៣ ជាន់ទី៤ និងជាន់ទី៥) មហាវិថីម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និង ចែកចាយទំនិញ

-ពាណិជ្ជកម្ម :ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សព្វផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

